អគ្គនាយកដ្ឋានកសិកម្ម

នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ

# នីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ សម្រាប់ការនាំចេញផលិតផលកសិកម្ម

រាជធានីភ្នំពេញ ថ្ងៃទី០៩-១១ ខែធ្នូ ឆ្នាំ២០១៩

ដោយ **ហ៊ាន សេរីវុធ** អនុប្រធានការិយាល័យភូតគាមអនាម័យ
នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ

## ក. សេចក្ដីផ្ដើម

- ការត្រួតពិនិត្យភូតគាមអនាម័យ មានគោលបំណងដើម្បីទប់ស្កាត់ការរីករាលដាលឆ្លងនូវសមាសភាពចង្រៃភូតគាម អនាម័យ និងសមាសភាពចង្រៃបង្កគ្រោះថ្នាក់ពីតំបន់មួយទៅតំបន់មួយទៀតក្នុង ព្រះរាជាណាចក្រកម្ពុជា ចូល-ចេញ ឬ ឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជាតាមគ្រប់មធ្យោបាយ ដើម្បីការពារផលិតកម្មកសិកម្ម និងជីវសាស្រ្តចម្រុះ។
- ម្ចាស់ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលនាំយក ឬ ដឹកជញ្ជូនចូល-ចេញ ឬ ឆ្លងកាត់ ព្រះរាជាណាចក្រកម្ពុជា ត្រូវសុំការត្រួតពិនិត្យ និងត្រូវគោរពតាមគ្រប់វិធានការភូតគាមអនាម័យ។
- នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចទទួលខុសត្រូវលើការអនុវត្តដោយផ្ទាល់នូវការងារត្រួតពិនិត្យភូតគាមអនាម័យ។

## ក. សេចក្តីផ្តើម

- ការផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់ការនាំចេញ ការនាំចេញទៅវិញ នាំចូល ត្រូវបានអនុវត្តតាម
  - អនុក្រឹត្យលេខ១៥ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ
  - ប្រកាសលេខ ៣៤៦ ប្រក.កសក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០ ស្តីពីនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ
  - កិច្ចសន្យាពាណិជ្ជកម្ម កិច្ចព្រមព្រៀង អនុសញ្ញា និងបណ្តាឯកសារដទៃទៀតស្តីពីលក្ខខណ្ឌភូតគាមអនាម័យនៃប្រទេសនាំចូល
- ការត្រួតពិនិត្យភូតគាមអនាម័យលើការដឹកជញ្ជូនទំនិញឆ្លងកាត់ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវគោរពតាមបទបញ្ញាត្តិ
  - អនុក្រឹត្យលេខ១៥ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ
  - ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៨ស្តីពីវិធានការអនាម័យ និងភូតគាមអនាម័យ និងកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានអំពីការសម្របសម្រួលទំនិញឆ្លងកាត់ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៨
  - ពិធីសារទី៧ស្តីពីប្រព័ន្ធឆ្លងកាត់គយចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥

## ខ. បែបបទនៃការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចេញ

- រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងនាំចេញនូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវជួបពិភាក្សាជាមួយសមត្ថកិច្ចភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម។ បែបបទនៃការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចេញ អាស្រ័យទៅនឹងប្រភេទទំនិញ ទីកន្លែងប្រភពទំនិញ និងដែនដី ឬប្រទេសជាទិសដៅនៃការនាំចូល (លក្ខខណ្ឌតម្រូវភូតគាមអនាម័យរបស់ប្រទេសនីមួយៗអាចខុសគ្នាអាស្រ័យទៅនឹងទីកន្លែងប្រភព និងប្រភេទផលិតផល)។ ជាទូទៅ បែបបទនៃការនាំចេញ (ត្រូវបំពេញមុនការនាំចេញ) អាចបែងចែកជា:
  - ប្រភេទទំនិញមិនជាប់កម្រិតកំណត់: ការនាំចេញទំនិញប្រភេទនេះពីកម្ពុជាទៅកាន់ប្រទេស ឬដែនដីដែលធ្លាប់បាននាំចេញរួចហើយ (រដ្ឋាភិបាលទាំងនោះមិនបានដាក់លក្ខខណ្ឌពិសេស ឬតម្រូវឱ្យសមត្ថកិច្ចនៃរដ្ឋាភិបាលប្រទេសនាំចេញស្នើសុំ តែផ្អែកលើលក្ខខណ្ឌផ្លូវច្បាប់ដែលមានជាធរមានរួចហើយ ដែលលក្ខខណ្ឌទាំងនោះ រាល់ការនាំចូលត្រូវ តែគោរព និងចាត់ចែងឱ្យមានអនុលោមភាពតាមវិធានការភូតគាមអនាម័យដែលមានជាធរមាន)។

## ក. បែបបទនៃការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចេញ

- ប្រភេទទំនិញជាប់កម្រិតកំណត់ : ការនាំចេញទំនិញប្រភេទនេះ (ទំនិញដែលមានសក្តានុពលហានិភ័យសមាសភាពចង្រៃខ្ពស់ដូចជាពពួកបន្លែ ផ្លែឈើ មើម និងបណ្តាទំនិញដទៃទៀតដែលចាត់ក្នុងកម្រិតហានិភ័យនៃស្តង់ដារភូតគាមអនាម័យអន្តរជាតិលេខ៣២ ក្នុងក្រុមទី៣ និងទី៤ ស្តីពីចំណាត់ថ្នាក់ទំនិញអាស្រ័យលើកម្រិតហានិភ័យបង្កឡើងដោយសមាសភាពចង្រៃ) ទាមទារឱ្យសមត្ថកិច្ចភូតគាមអនាម័យកម្ពុជា ធ្វើសំណើសុំចរចារជាមួយសមត្ថកិច្ចភូតគាមអនាម័យនៃប្រទេសនាំចូល តាមរយៈការស្នើសុំវាយតម្លៃហានិភ័យសមាសភាពចង្រៃពាក់ព័ន្ធនឹងការនាំចូលទំនិញដែលបានស្នើសុំ។ ការចរចារអាចចំណាយពេលពី១ ដល់៥ឆ្នាំ ដែលការនាំចេញពីកម្ពុជាអាចចាប់ផ្តើមបន្ទាប់ពីមានកិច្ចព្រមព្រៀង ពិធីសារ ឬឯកសារសមមូល បញ្ជាក់ពីការឯកភាពរវាងសមត្ថកិច្ចភូតគាមអនាម័យនៃប្រទេសទាំងពីរ។ កិច្ចឯកភាពនេះ អាចមានរហូតកម្រិតតំបន់ ដូចជា ASEAN Trade in Goods Agreement (ATIGA) នៃអាស៊ានជាដើម។
  - ជាក់ស្តែង ការបើកទីផ្សារអង្ករ និងដំឡូងមីក្រៀមជាមួយប្រទេសចិនបានចំណាយរយៈពេលអស់០៦ឆ្នាំ (២០០៤-២០១០) សម្រាប់គ្រាប់ពោត ចំណាយរយៈពេលអស់០៤ឆ្នាំ (២០១១-២០១៤) ផ្លែចេកចំណាយរយៈពេលអស់០៥ឆ្នាំ (២០១៤-២០១៨)។ ដោយឡែក ការបើកទីផ្សារផ្លែស្វាយជាមួយប្រទេសកូរ៉េ ចំណាយរយៈពេលអស់ ០៧ឆ្នាំ (២០០៩-២០១៥) តែនៅតែមិនអាចនាំចេញបានដោយហេតុថា នៅមិនទាន់អាចបំពេញតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃប្រទេសកូរ៉េ)។

**ជំហានជាលំដាប់លំដោយដូចខាងក្រោម៖**

- រៀបចំលិខិតស្នើសុំនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ
- ការរៀបចំជាឯកសារបច្ចេកទេសដោយប្រទេសនាំចេញ
- ទំនាក់ទំនងជាមួយនឹង NPPO នៃប្រទេសនាំចូល
- រៀបចំធ្វើ PRA ដោយ NPPO នៃប្រទេសនាំចូល
- ផ្ញើការទំនាក់ទំនងនៃលទ្ធផល PRA ទៅកាន់ប្រទេសនាំចូល (ចរចាពីសមាសភាពចម្រៀងភូតគាមអនាម័យ)
- ការចុះពិនិត្យជាក់ស្តែងដល់ទីតាំងចម្ការ
- ការពិគ្រោះយោបល់លើលក្ខខណ្ឌនាំចូល
- បញ្ជាប់នូវលក្ខខណ្ឌនាំចូល

## ប្រភេទពត៌មានដែលមានសារៈសំខាន់ក្នុងការដាក់ស្នើសុំបើកទីផ្សារ

- ដំណាំៈ ប្រភេទ / ពូជ
- ទីតាំងផលិតកម្ម / បរិមាណ / រដូវកាល
- វិធីសាស្ត្រដាំដុះ : ការគ្រប់គ្រងសមាសភាពចង្រៃ  ការធ្វើអង្កេត  ការប្រមូលផល
- បញ្ជីសមាសភាពចង្រៃ/តារាងទិន្នន័យៈ  អ្នកកំណត់ឈ្មោះ ឈ្មោះទូទៅ ប្រភេទជម្រក ផ្នែករុក្ខជាតិរងការបំផ្លាញ លក្ខណៈជីវសាស្ត្រ វិធានការកម្ចាត់
- ទីតាំងវេចខ្ចប់ៈ ការងារក្រោយពេលប្រមូលផល និងប្រព្រឹត្តកម្ម, ការស្តុកទុក និងការវេចខ្ចប់
- កម្មវិធីនាំចេញៈ ទិសដៅទីផ្សារ, លក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃប្រទេសនាំចូល
- ទិសដៅនៃការនាំចេញនាពេលបច្ចុប្បន្ន, ការនាំចេញនូវផលិតផលដូចគ្នាទៅកាន់ប្រទេសទីបី
- ឯកសារយោង និងសំណុំឯកសារសំខាន់ៗថតចម្លង

# ការចរចាលក្ខខណ្ឌនាំចូល

## បន្ទាប់ពីការធ្វើវិភាគហានិភ័យសមាសភាពចង្រៃ (PRA)

- បញ្ចប់នូវលក្ខខណ្ឌនាំចូលដោយផ្អែកលើការយល់ព្រមអំពីការធ្វើវិភាគហានិភ័យ
  - ការដោះដូរលិខិតស្នាមៈ អនុស្សរៈយោគយល់គ្នា (MOU), ពិធីសារ (Protocol)
  - ផែនការការងារ



- ❑ ដំណាក់កាលទី១: ការដាក់ពាក្យសុំ

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងនាំចេញនូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យទៅកាន់ប្រទេស ឬដែនដីនៃប្រទេស ត្រូវដាក់ពាក្យបំពេញបែបបទស្នើសុំ (១០ថ្ងៃមុនមានការកំណត់នាំចេញ) ការត្រួតពិនិត្យភូតគាមអនាម័យលើ ទំនិញបញ្ញើបម្រុងនាំចេញនៅអគ្គនាយកដ្ឋានកសិកម្ម (នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ)។

សំណុំឯកសារស្នើសុំត្រូវភ្ជាប់មកជាមួយនូវ:



- វិក្កយបត្រ (Invoice) និងបញ្ជីវេចខ្ចប់ (Packing list)
- វិញ្ញាបនបត្រផ្សែងកម្ម (Fumigation certificate)
  (ប្រសិនបើមាន និងត្រូវតែមានប្រសិនបើមានការតម្រូវពីប្រទេសនាំចូល)
- លិខិតអនុញ្ញាតនាំចូល (Import Permit issued by the importing country) (ប្រសិនបើមាន)
- បណ្ដាលក្ខខណ្ឌភូតគាមអនាម័យនៃប្រទេសនាំចូល ក្នុងសណ្ឋានជាកិច្ចព្រមព្រៀង ពិធីសារ...(ប្រសិនបើមាន)
- វិញ្ញាបនបត្រភូតគាមអនាម័យ (Phytosanitary Certificate) ដែលចេញដោយសមត្ថកិច្ចភូតគាមអនាម័យនៃប្រទេសជាប្រភពដើមនៃទំនិញ (ក្នុងករណីសុំនាំចេញទៅវិញ)។

## ដំណាក់កាលទី២: ការត្រួតពិនិត្យទំនិញបញ្ញើ

សមត្ថកិច្ចភូតគាមអនាម័យនៃនាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្មនឹងចុះធ្វើការវាយតម្លៃហានិភ័យលើផលិតផលតាមការស្នើសុំ ប្រសិនបើទំនិញបញ្ញើ:

- គ្មានសមាសភាពចង្រៃ និងគ្មានសញ្ញាសង្ស័យ
- មានសមាសភាពចង្រៃតែមានអនុលោមភាព
- មានសមាសភាពចង្រៃ និង/ឬមានសញ្ញាសង្ស័យថាមានសមាសភាពចង្រៃដែលបានធ្វើអត្តសញ្ញាណកម្មដោយភ្នែក
- ប្រវត្តិរបស់ក្រុមហ៊ុន ប្រភពដើមរបស់ផលិតផល

បន្ទាប់មកសមត្ថកិច្ចនៃនាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្មនឹងធ្វើការណែនាំពីលក្ខខណ្ឌតម្រូវនាំចេញផលិតផលពីប្រទេសកម្ពុជាដល់អ្នកនាំចេញ។





## ❑ ដំណាក់កាលទី៣: ការពិនិត្យ វិនិច្ឆ័យនៅមន្ទីរពិសោធន៍

សមត្ថកិច្ចរបស់នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងធ្វើការពិនិត្យថា តើប្រទេសនាំចូល តម្រូវឱ្យធ្វើតេស្ត និងអធិការកិច្ចអ្វីខ្លះ។ បន្ទាប់មកនាយកដ្ឋាន នឹងរៀបចំធ្វើអធិការកិច្ច និងតេស្តទៅតាមការទាមទារនៃប្រទេសនាំចូល។

- ករណីអាចមានអនុលោមភាព
- ករណីអាចកែតម្រូវ (ធូបនកម្ម) ឱ្យមានអនុលោមភាព
- ករណីអាចថាមិនអាចកែតម្រូវឱ្យមានអនុលោមភាព (បដិសេធ)។

ប្រសិនបើចាំបាច់ សមត្ថកិច្ចនៃនាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម នឹងរៀបចំធ្វើតេស្តនៅក្នុងមន្ទីរពិសោធន៍ដោយប្រើពេលយ៉ាងហោចណាស់ឱ្យបានមុនការនាំចេញចំនួន១០ថ្ងៃ (គិតតែថ្ងៃធ្វើការប៉ុណ្ណោះ)។ ការរៀបចំធ្វើតេស្តដែលចាំបាច់ទាំងអស់ អ្នកនាំចេញត្រូវបានធ្វើការជូនដំណឹងជាមុន បន្ទាប់ពីមានតម្រូវការពីប្រទេសនាំចូល។



- ដំណាក់កាលទី៤: ការកែតម្រូវទំនិញឱ្យស្របតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃប្រទេសនាំចូល

ប្រសិនបើចាំបាច់ សមត្ថកិច្ចនៃនាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម ឬ (ក្រុមហ៊ុនដែលបានចុះបញ្ជិកាទទួលស្គាល់ដោយអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) នឹងមានរៀបចំធ្វើធូបនកម្ម យ៉ាងហោចណាស់ឱ្យបានមុនការនាំចេញរយៈពេល១០ថ្ងៃ (គិតតែថ្ងៃធ្វើការប៉ុណ្ណោះ)។ ដំណើរការធូបនកម្មត្រូវចំណាយពេលចំនួន ១០-១២០ម៉ោង។ សមត្ថកិច្ចនៃនាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម នឹងធ្វើការត្រួតពិនិត្យក្រោយពេលធ្វើធូបនកម្ម ដើម្បីកំណត់ថាតើចាំបាច់ត្រូវធ្វើធូបនកម្មម្តងទៀតដែរឬទេ?



- ដំណាក់កាលទី៤: ការកែតម្រូវទំនិញឱ្យស្របតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃប្រទេសនាំចូល

  ក្នុងករណីដែលមានវត្ថុមានសមាសភាពចង្រៃក្នុងពេលត្រួតពិនិត្យ និង/ឬលទ្ធផលនៃការវិភាគនៅមន្ទីរពិសោធន៍ ដែលបញ្ជាក់ថា ទំនិញមិនស្របតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃប្រទេសនាំចូល សមត្ថកិច្ចត្រូវតម្រូវឱ្យម្ចាស់ទំនិញ ចាត់វិធានការកែតម្រូវ (ប្រសិនបើអាចកែតម្រូវបាន) ដូចជាធ្វើការកម្ចាត់សមាសភាពចង្រៃដោយប្រើឧស្ម័នពុល (Fumigation) ដែលត្រូវចំណាយពេលបន្ថែមរហូតដល់៥ថ្ងៃ។

  ផ្ទុយទៅវិញ ក្នុងករណីមិនអាចកែប្រែបាន សមត្ថកិច្ចអាចស្នើសុំបដិសេធការចេញផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យ (មិនអាចនាំចេញបាន)។

  ក្នុងករណីដែលលទ្ធផលត្រួតពិនិត្យទំនិញបញ្ញើរខាងលើ អាចឱ្យសមត្ថកិច្ចធ្វើការសន្និដ្ឋានបានថា ទំនិញបញ្ញើរដែលបានត្រួតពិនិត្យពិតជាមាន ឬមិនមានអនុលោមភាពតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃប្រទេសនាំចូល នោះអាចលោតទៅដល់ដំណាក់កាលទី៥។

- ដំណាក់កាលទី៥: ការចេញផ្តល់ ឬបដិសេធផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យ

យោងតាមការសន្និដ្ឋានក្នុងរបាយការណ៍ត្រួតពិនិត្យរបស់សមត្ថកិច្ច (លទ្ធផលនៃការត្រួតពិនិត្យដោយភ្នែកទទេរ ដោយការវិភាគ ដោយការពិនិត្យឡើងវិញបន្ទាប់ពីកែតម្រូវទំនិញ) នោះទំនិញបញ្ញើរដែលស្នើសុំ និងត្រូវទទួលបានការបដិសេធ ឬការផ្តល់ជូននូវវិញ្ញាបនបត្រភូតគាមអនាម័យ។




**សូមចូលទៅកាន់គេហ៍ទំព័ររបស់អគ្គនាយកដ្ឋានកសិកម្ម**

http://gda.maff.gov.kh/documentcategory/387LgUr3R6

ដើម្បីទទួលបាននូវព័ត៌មានដូចបានរៀបរាប់ខាងលើ

# ផលិតផលកសិកម្មនាំចេញសរុបក្នុងឆ្នាំ២០១៣-២០១៨ (តោន)




សូមអរគុណ